# ជំពូកទី ២

## ២. ច្បាប់ និង បញ្ញត្តិជាប់ទាក់ទង

### ២.១ ស្ថាប័នសំខាន់ៗ

គំរោងវារីអគ្គិសនីស្នើសុំ គឺមានការត្រួតពិនិត្យលើការរៀបចំរចនាប្លង់វិស្វកម្មដោយផ្ទាល់ពីអាជ្ញាធរអគ្គិសនីកម្ពុជា (EAC) និងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល (MIME)។ យោងលើទីតាំងគំរោងស្ថិតនៅក្នុងខេត្តស្ទឹងត្រែង និងជាប់ទាក់ទិននឹងកិច្ចការពារ និងការគ្រប់គ្រងធនធានធម្មជាតិដែលមាននៅក្នុងខេត្តនេះ នោះស្ថាប័នសំខាន់ៗដែលពាក់ព័ន្ធនឹងការសាងសង់ និងប្រតិបត្តិការគំរោង រួមមាន អាជ្ញាធរខេត្តស្ទឹងត្រែង, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF), និងក្រសួងបរិស្ថាន (MoE)។ ពាក់ព័ន្ធនឹងការផ្លាស់ទី ឬការតាំងលំនៅដ្ឋានឡើងវិញរបស់ប្រជាជន ឬសហគមន៍រងផលប៉ះពាល់ នោះស្ថាប័នសំខាន់រួមមានគណៈកម្មការអន្តរក្រសួងរៀបចំការតាំងលំនៅសារជាថ្មី (IRC) ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF), ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ (MLMUPC), ព្រមទាំងអាជ្ញាធរដែនដី ។ ទាក់ទិននឹងធនធានទឹកគឺក្រសួងធនធានទឹក និងឧតុនិយម (MoWRAM) ដែលជាស្ថាប័នសំខាន់ យោងតាមច្បាប់គ្រប់គ្រងធនធានទឹក។ ដោយគំរោងមានការវិនិយោគទ្រង់ទ្រាយធំ នោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយគណៈកម្មាធិការអភិវឌ្ឍន៍កម្ពុជា (CDC) ជាស្ថាប័នចំបងក្នុងកិច្ចការសំរេចលើគំរោងវិនិយោគទុនបែបនេះ ។

### ២.២ ដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ប្រើជាឧបករណ៍ផែនការបរិស្ថាន សំរាប់គំរោងអភិវឌ្ឍន៍នានា ដែលមាននៅក្នុងប្រទេសកម្ពុជា ដោយទាមទារថា "ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តលើរាល់គំរោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យនិងវាយតំលៃដោយក្រសួងបរិស្ថាន មុនដាក់ជូនរាជរដ្ឋាភិបាលសំរេច" (មាត្រា ទី៦ នៃច្បាប់) ។ អនុក្រឹត្យស្តីអំពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន មានការទាមទារថា ត្រូវដាក់ជូននូវរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ព្រមជាមួយនឹងរបាយការណ៍ការសិក្សាសមិទ្ធិលទ្ធភាព របស់គំរោងទៅក្រសួងបរិស្ថានដើម្បីពិនិត្យ និងអនុម័ត ។ ដំណើរការនេះបាននឹងកំពុងអនុវត្តតាមដោយគំរោងបច្ចុប្បន្ន ហើយម្ចាស់គំរោង "EVN/PECC1" ចាំបាច់ត្រូវដាក់ជូននូវរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ជាមួយនឹងរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាព របស់គំរោងរោងចក្រវារីអគ្គិសនីសេសានក្រោមទី ២ ទៅអោយក្រសួងបរិស្ថាន។

គំនូសបំព្រួញខាងក្រោមបង្ហាញពីដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានសំរាប់គំរោងស្នើសុំ ដែលបានអនុម័តដោយរាជរដ្ឋាភិបាល (RGC) ឬ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)។

Draft

## កិច្ចដំណើរការ វ.ហ.ប សំរាប់គំរោងស្នើសុំ ដែលអនុម័តដោយរាជរដ្ឋាភិបាល ឬ ក.អ.ក




## ២.៣ នីតិកម្ម និង គោលការណ៍ណែនាំ

ច្បាប់សំខាន់ៗ អនុក្រឹត្យ និង គោលការណ៍ណែនាំ សំខាន់ៗមួយចំនួន ដែលប្រើប្រាស់ចំពោះគំរោងរោងចក្រវារីអគ្គិសនីសេសានក្រោម ២ មានដូចតទៅ:

### ក) ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣

ក្នុងផ្នែកសេដ្ឋកិច្ចក្នុងជំពូកទី ៥ នៃរដ្ឋធម្មនុញ្ញបានចែងថា:

-ទ្រព្យសម្បត្តិរបស់រដ្ឋរួមមានដី ធនធានក្រោមដី ភ្នំ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆក/ឆ្នេរ បរិយាកាស កោះ ទន្លេ ព្រែក ស្ទឹង/អូរ បឹង ព្រៃ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ច មូលដ្ឋានការពារជាតិ រចនាសម្ព័ន្ធផ្សេងៗ ទៀតចាត់ជាកម្មសិទ្ធិរបស់រដ្ឋ តាមមាត្រាទី ៥៨។

-រដ្ឋាភិបាលត្រូវការពារបរិស្ថាន និង ថ្លឹងថ្លែងពីធនធានធម្មជាតិ និង គ្រប់គ្រងដោយមានផែនការត្រឹមត្រូវនៅលើដី ទឹក ខ្យល់ បរិយាកាស ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ឥន្ធនៈ និង ឧស្ម័ន ថ្ម និង ខ្សាច់ ត្បូងថ្មមានតំលៃ ព្រៃឈើ និង អនុផលព្រៃឈើ សត្វព្រៃ ត្រី និង ធនធានក្នុងទឹក មាត្រាទី ៥៩។

-រដ្ឋាភិបាលជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅក្នុងគ្រប់ផ្នែកទាំងអស់ និង នៅតាមតំបន់ដាច់ស្រយាល ជាពិសេស

Draft

កសិកម្ម សិប្បកម្ម ឧស្សាហកម្ម ដោយមានការយកចិត្តទុកដាក់ចំពោះនយោបាយទឹក អគ្គិសនី ផ្លូវថ្នល់ មធ្យោបាយដឹកជញ្ជូនផ្សេងៗ បច្ចេកវិទ្យាទំនើប និង ប្រព័ន្ធគណនាទាន តាមមាត្រាទី ៦១ ។

## ខ) ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ត្រូវបានអនុម័តដោយរដ្ឋសភាជាតិ និង ប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម ១២៩៦-៣៦។ ច្បាប់នេះបានអនុម័តនៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ។ ច្បាប់នេះមានគោលបំណងដូចតទៅ:

- ការពារ និង លើកកំពស់គុណភាពបរិស្ថាន និង សុខភាពពលរដ្ឋ ដោយធ្វើការទប់ស្កាត់ ការកាត់បន្ថយ និង ការត្រួតពិនិត្យការបំពុល ។
- វាយតំលៃហេតុប៉ះពាល់បរិស្ថានមុននឹងចេញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ចំពោះរាល់គំរោងដែលបានស្នើឡើង។
- ធានាឱ្យមានការអភិរក្ស ការអភិវឌ្ឍន៏ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយ និរន្តរភាព និង ភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ។
- លើកទឹកចិត្ត និងផ្តល់លទ្ធភាពឱ្យសាធារណជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ។
- បង្ក្រាបអំពើទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន ។

Draft

នៅក្រោមច្បាប់នេះ អ្នកអភិវឌ្ឍន៏ទាំងឡាយចាំបាច់ត្រូវរៀបចំរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ឬ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) សំរាប់គំរោងអភិវឌ្ឍន៏ដែលស្នើសុំ ឬ ដែលមានស្រាប់ដូចមានរៀបរាប់នៅក្នុងមាត្រាដូចតទៅ:

**មាត្រា ៦:**

ការវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តលើគំរោង និងសកម្មភាពរបស់ឯកជន ឬ សាធារណៈហើយ ត្រូវបានពិនិត្យ និងវាយតំលៃដោយក្រសួងបរិស្ថាន មុនដាក់ជូនរាជរដ្ឋាភិបាលសំរេច ។

**មាត្រា ៧:**

ចំពោះរាល់ពាក្យសុំធ្វើគំរោងវិនិយោគ និងរាល់គំរោងដែលរដ្ឋស្នើឡើង ត្រូវមានភ្ជាប់ជាមួយនឹងការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA)ឬ ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) ដូចមានចែងក្នុងមាត្រា៦ នៃច្បាប់នេះ ។ ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់លើ (IEIA) ឬ (EIA) ទៅអង្គការមានសមត្ថកិច្ចក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៩:**

ធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលមានជាអាទិ៍ ដី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និង ឧស្ម័ន ថ្មនិងខ្សាច់ ត្បូងថ្មមានតំលៃ ព្រៃឈើនិងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល ត្រូវបានអភិរក្ស អភិវឌ្ឍន៍ និងគ្រប់គ្រង ហើយប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយលក្ខណៈនិរន្តរភាព ។

## គ) ព្រះរាជក្រឹត្យស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ

ព្រះរាជក្រឹត្យស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិត្រូវបានអនុម័តដោយរដ្ឋសភាជាតិ ហើយបានដាក់អោយប្រើប្រាស់ ដោយព្រះរាជក្រឹត្យ/០១ ចុះខែវិច្ឆិកា ឆ្នាំ ១៩៩៣។

ព្រះរាជក្រឹត្យមានចែងដូចខាងក្រោមៈ

**មាត្រា ១:** ការទទួលខុសត្រូវលើតំបន់ការពារធម្មជាតិ

រដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិស្ថានទទួលខុសត្រូវ ក្នុងការដឹកនាំគ្រប់គ្រងធ្វើផែនការ និង អភិវឌ្ឍន៍ប្រព័ន្ធតំបន់ការពារធម្មជាតិរបស់ជាតិ រួមមានការការពារបរិស្ថាន ដី ព្រៃឈើ តំបន់ដីសើម និង តំបន់ឆ្នេរ។ រដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិស្ថានមានសិទ្ធិអំណាចបង្កើត និង ធ្វើជាប្រធានគណៈកម្មាធិការសម្រប សំរាប់សម្របសម្រួលអន្តរក្រសួងលើបន្ទាត់នយោបាយ និង បច្ចេកទេស។ ការគ្រប់គ្រង និង អភិបាលប្រព័ន្ធតំបន់ការពារធម្មជាតិរបស់ជាតិ ជាការទទួលខុសត្រូវរួមរបស់រដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិស្ថាន ដោយសហការជាមួយស្ថាប័នមានសមត្ថកិច្ចឯទៀត។

ប្រព័ន្ធនេះរួមបញ្ចូលរាល់ប្រភេទដែនបំរុងសំរាប់គោលដៅគ្រប់គ្រងដូចតទៅ:

**១- ឧទ្យានជាតិ:** ដែនធម្មជាតិ និង ទស្សនីយភាពដែលត្រូវការពារ ដើម្បីបំរើអោយវិទ្យាសាស្ត្រ ការអប់រំ និង ការកំសាន្ត។

**២-ដែនជំរកសត្វព្រៃ:** ដែនធម្មជាតិដែលធានានូវលក្ខខណ្ឌធម្មជាតិ ចាំបាច់ក្នុងការការពារប្រភេទសត្វព្រៃ និង រុក្ខជាតិរបស់ជាតិសំខាន់ៗ និង សហគមន៍ធម្មជាតិ ឬ លក្ខណៈរូបសាស្ត្ររបស់បរិស្ថាន ជាទីដែលភាវៈទាំងនេះត្រូវការជាពិសេសនូវអន្តរាគមន៍ពីមនុស្សសំរាប់ភាពស្ថិតស្ថេររបស់វា។

**៣- តំបន់ការពារទេសភាព:** តំបន់ដែលត្រូវថែទាំទេសភាពធម្មជាតិ និង ពាក់កណ្តាលធម្មជាតិសំខាន់ៗ សំរាប់រមណីយដ្ឋានដល់សាធារណៈជនក្នុងការសំរាកកំសាន្ត និង ធ្វើទេសចរណ៍។

**៤- តំបន់ដែលទទួលរងនូវការប្រើប្រាស់ច្រើនមុខ:** តំបន់ដែលផ្តល់នូវភាពស្ថិតស្ថេរលើប្រភពទឹក ព្រៃឈើ សត្វព្រៃ ត្រី វាលស្មៅ និងការកំសាន្តដោយតំរូវអោយមានការអភិវឌ្ឍន៍ អភិរក្សធម្មជាតិក្នុងគោលដៅចំបងនៃសកម្ម

ភាពសេដ្ឋកិច្ច ។

**មាត្រា ៧ :** វិសោធនកម្ម

បណ្ដាប្រព័ន្ធតំបន់ការពារធម្មជាតិ អាចនឹងកែប្រែពង្រីកបន្ថែមនៅពេលអនាគត ដោយផ្អែកលើព័ត៌មានវិទ្យាសាស្ត្រមូលដ្ឋាន ដែលទាក់ទងទៅនឹងអភិរក្សជីវសាស្ត្រ និង ការរក្សាអោយមានភាពស្ថិតស្ថេរ នៃទេសភាពនៅព្រះរាជាណាចក្រកម្ពុជា ។

## ឃ) អនុក្រឹត្យ ស្ដីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្ដីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន បានអនុម័តនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩ ។ មាត្រាពាក់ព័ន្ធសំខាន់ៗរួមមានដូចខាងក្រោមៈ

**មាត្រា ១:** អនុក្រឹត្យនេះមានគោលបំណង :

- កំណត់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន លើរាល់គំរោង និងសកម្មភាពរបស់ឯកជន ឬ សាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃដោយក្រសួងបរិស្ថានមុននឹងដាក់ជូនរាជរដ្ឋាភិបាលសំរេច ។
- កំណត់ប្រភេទ និងទំហំគំរោង សកម្មភាពដែលបានស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ទាំងឯកជន ទាំងសាធារណៈ ដែលត្រូវវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។
- បំផុសឱ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណាក្នុងកិច្ចដំណើរការអនុម័តគំរោង ។

**មាត្រា ២:**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគំរោងដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ដែលជាបុគ្គលឯកជន ជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចំរុះរដ្ឋ ឬជាក្រុមហ៊ុនរដ្ឋ ជាក្រសួង-ស្ថាប័នរដ្ឋ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ លើកលែងតែគំរោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ ដែលសំរេចដោយរាជរដ្ឋាភិបាល ។

**មាត្រា ៣:** ក្រសួងបរិស្ថានមានភារៈកិច្ច :

ក/- ពិនិត្យ និងវាយតំលៃលើ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន EIA ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

ខ/- តាមដានឃ្លាំមើល និងចាត់វិធានការ អោយម្ចាស់គំរោងប្រតិបត្តិតាម ផែនការគ្រប់គ្រងបរិស្ថានក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គំរោង ដូចមានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានអនុម័តរួច ។

Draft

**មាត្រា ៩:** ម្ចាស់គំរោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ និង របាយការណ៍សិក្សាសមិទ្ធិលទ្ធភាពទៅក្រសួងបរិស្ថាន ចំពោះគំរោងដែលអាចបង្កហេតុប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ ដល់ធនធានធម្មជាតិ សេដ្ឋកិច្ច ប្រព័ន្ធសុខភាព និងសុខមាលភាពសាធារណៈ ។

**មាត្រា ១៧:** ក្រសួងបរិស្ថាន ត្រូវពិនិត្យរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៦ ព្រមទាំងចាត់បញ្ជូនយោបល់ និងសំណើទៅម្ចាស់គំរោង និងស្ថាប័នអនុម័តគំរោងក្នុងរយៈពេល ៣០ ថ្ងៃ គិតថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលក្រសួងបានទទួលរបាយការណ៍សិក្សាលទ្ធភាព និង របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញពីម្ចាស់គំរោង ។

**មាត្រា ២០:** មុនចាប់ដំណើរការអនុវត្តគំរោង ម្ចាស់គំរោងត្រូវទទួលយោបល់ឯកភាពពីក្រសួងបរិស្ថានលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

## ខ) អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក

អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក បានអនុម័តនៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩ ។ អនុក្រឹត្យនេះ មានគោលដៅកំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និង កាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ ។

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយ ដែលបង្កឱ្យមានការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ ។

អនុក្រឹត្យនេះមានរៀបចំតាមប្រភេទនៃការបំពុល, បទដ្ឋាននៃការបញ្ចេញចោល, បទដ្ឋានគុណភាពទឹកនៅតាមតំបន់នានា ។ ឧបសម្ព័ន្ធចំពោះអនុក្រឹត្យនេះផ្តល់នូវៈ

-ប្រភេទសារធាតុគ្រោះថ្នាក់

-បទដ្ឋាននៃការបញ្ចេញចោលសំរាប់ប្រភពបំពុលចេញពីទឹកក្រខ្វក់ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬទឹកស្អុយ

-ប្រភេទប្រភពបំពុលតំរូវអោយមានការអនុញ្ញាតិពីក្រសួងបរិស្ថាន មុននឹងបង្ហូរបញ្ចេញ ឬដឹកជញ្ជូនទឹកក្រខ្វក់របស់វា ។

-បទដ្ឋានគុណភាពទឹកនៅក្នុងតំបន់សាធារណៈសំរាប់ការអភិរក្សជីវៈចំរុះ

-បទដ្ឋានគុណភាពទឹកនៅក្នុងតំបន់សាធារណៈសំរាប់ការពារសុខភាពសាធារណៈ ។

## ច) អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង

អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង បានអនុម័តនៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩ ។ គោលបំណងរបស់អនុក្រឹត្យនេះគឺដើម្បីធ្វើនិយ័តកម្មការគ្រប់គ្រងកាកសំណល់តាមលក្ខណៈបច្ចេកទេសសមស្រប និង តាមវិធីសាស្ត្រសុវត្ថិភាព ដើម្បីធានាបានពីការការពារសុខភាពមនុស្ស និង ការអភិរក្សជីវៈចំរុះ ។



Draft

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត ចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

## ឆ) ច្បាប់ភូមិបាល

ច្បាប់ភូមិបាលនេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០១។ មាត្រាទាក់ទងសំខាន់ៗមានដូចខាងក្រោមៈ

<u>មាត្រា ៣</u>: ជនគ្រប់រូបត្រូវគោរពទ្រព្យសម្បត្តិរបស់រដ្ឋ និងកម្មសិទ្ធិឯកជនស្របច្បាប់លើអចលនវត្ថុ។

ការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយោដី លើអចលនវត្ថុដែលជាទ្រព្យសម្បតិរបស់រដ្ឋ និង ការចេញប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ។ បទបញ្ជា និងនិតិវិធី នៃការគ្រប់គ្រងអចលនវត្ថុដែលជាទ្រព្យសម្បតិរបស់រដ្ឋ នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

<u>មាត្រា ៥</u>: គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ។ ការដកហូតត្រូវធ្វើទៅតាមទម្រង់ និង និតិវិធីបញ្ញត្តិដោយច្បាប់ និងបទបញ្ញាបន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។

<u>មាត្រា ៧</u>: របបកម្មសិទ្ធិអចលនវត្ថុមុនឆ្នាំ ១៩៧៩ មិនត្រូវបានទទួលស្គាល់។

<u>មាត្រា ២៣</u>: សហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និង សេដ្ឋកិច្ចប្រតិបត្តិ របៀបរស់នៅតាមប្រពៃណី និង ដាំដុះលើដី ដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទំលាប់ នៃការប្រើប្រាស់ជាសមូហភាព។

ក្នុងពេលរង់ចាំការកំណត់ខាងផ្លូវច្បាប់នូវលក្ខខន្តិកៈរបស់សហគមន៍ ក្រុមដែលមានជាក់ស្តែងមកទល់បច្ចុប្បន្ននេះនឹងបន្តគ្រប់គ្រងសហគមន៍និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណី ហើយត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ។

<u>មាត្រា ៣០</u>: បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធីនិងមិនមានការជំទាស់ចាប់ពី៥ (ប្រាំ) ឆ្នាំយ៉ាងតិចគិតមកដល់កាលបរិច្ឆេទនៃការប្រកាសអោយប្រើច្បាប់នេះលើអចលនវត្ថុ ដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុងការកាន់កាប់ជាឯកជន មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ។

ក្នុងករណីមានការជំទាស់ដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិស្ថាពរនេះ អ្នកតវ៉ាត្រូវយកភស្តុតាងមកបញ្ជាក់ថា ខ្លួនឯងផ្ទាល់បានបំពេញលក្ខខណ្ឌនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី៥ (ប្រាំ) ឆ្នាំ នៅលើអចលនវត្ថុដែលមានទំនាស់ឬយកភស្តុតាងដែលថាខ្លួនបានទិញអចលនវត្ថុនោះពីភាគីដើមឬពីសិទ្ធិវន្តស្របច្បាប់ឬអ្នកទទួលផ្ទេរកម្មសិទ្ធិឬពីសន្តតិជនរបស់ខ្លួន។

## ៥) ច្បាប់ព្រៃឈើ

ច្បាប់ព្រៃឈើត្រូវបានអនុម័តដោយសភាជាតិ និង ដាក់អោយប្រើប្រាស់ដោយព្រះរាជក្រម លេខ នស.រកម.០៨០២.០១៦ នៅថ្ងៃទី ៣១ សីហា ២០០២។ មាត្រាពាក់ព័ន្ធសំខាន់ៗមានដូចតទៅៈ

**មាត្រា ១ៈ**

ច្បាប់នេះកំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការប្រមូលផល ការប្រើប្រាស់ ការអភិវឌ្ឍន៍និងការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលបំណងនៃច្បាប់នេះគឺធានានូវការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន ៈចម្រុះ និងមរតកវប្បធម៌។

**មាត្រា ២ៈ**

ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់ព្រៃឈើទាំងអស់ ទោះជាប្រភេទព្រៃនោះកើតឡើងដោយធម្មជាតិក្តី ឬដោយដាំក្តី។ រដ្ឋធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីនូវផល អនុផលព្រៃឈើរបស់សហគមន៍មូលដ្ឋានក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ឬច្បាប់ពាក់ព័ន្ធផ្សេងទៀត។

**មាត្រា ៣ៈ**

ការគ្រប់គ្រងព្រៃឈើត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

ការគ្រប់គ្រងព្រៃលិចទឹកស្ថិតនៅក្រោមច្បាប់មួយដោយឡែក។

រដ្ឋផ្តល់សិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថាន ក្រោមបទប្បញ្ញត្តិ ទាំងឡាយនៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ចុះថ្ងៃទី ២៤ ធ្នូ ឆ្នាំ ១៩៩៦ ព្រះរាជក្រិត្យស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ និង លិខិតបទដ្ឋានច្បាប់ផ្សេងទៀត។

ក្រសួងកសិកម្ម រុក្ខប្រមាញ់ និង នេសាទមានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តន៍ច្បាប់ ចំពោះរាល់បទល្មើសព្រៃឈើ ដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិក្រោមការសម្របសម្រួលជាមួយក្រសួងបរិស្ថាន ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី ១៤ នៃច្បាប់នេះ។ សកម្មភាពនេះនឹងមិនធ្វើអោយប៉ះពាល់ដល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិឡើយ។

**មាត្រា ៤ៈ**

ក្នុងការអនុវត្តន៍ច្បាប់នេះ រាល់ការសម្រេចរបស់រាជរដ្ឋាភិបាលដែលមានសក្តានុពលភាពចំពោះផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជាពលរដ្ឋទូទៅ លើជីវភាពសហគមន៍មូលដ្ឋាន និងលើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជាត្រូវមានការចូលរួមជាសាធារណៈ។

សកម្មភាពចំបងៗពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ ដែលអាចបណ្តាលអោយមានផលប៉ះពាល់អាក្រក់ដល់សង្គមនិងបរិស្ថាន ចាំបាច់ត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាននិងផលប៉ះពាល់សង្គម ដោយផ្អែកតាមក្រុម

បច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជានិងស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ។ ឯកសារនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គមត្រូវផ្តល់ជូនសំរាប់ការចូលរួមផ្តល់មតិជាសាធារណៈបាន។

រាល់ការសំរេចចុងក្រោយលើរាល់សកម្មភាពចំបង១ ពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ រាជរដ្ឋាភិបាលត្រូវពិចារណាលើអនុសាសន៍ចុងក្រោយនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និង ផលប៉ះពាល់សង្គម។ ការសំរេចចុងក្រោយណាមួយក្រោមមាត្រានេះ រាជរដ្ឋាភិបាលអាចធ្វើការជូនដំណឹងជាសាធារណៈ។

**<u>មាត្រា ៩៩:</u>**

បុគ្គលណាដែលបានប្រព្រឹត្តិបទល្មើសព្រៃឈើធ្វើអោយប៉ះពាល់ខូចខាតដល់មជ្ឈដ្ឋានព្រៃឈើត្រូវចេញថ្លៃស្តារ ឬជួសជុលការខូចខាតអោយមានលក្ខខណ្ឌដូចដើមឡើងវិញ។

## *ឈ) ច្បាប់ជលផល*

ច្បាប់ជលផល ត្រូវបានចុះព្រះហស្តលេខា និងព្រះរាជលញ្ចករដោយ **នរោត្តម សីហមុនី** នៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៦។ មាត្រាពាក់ព័ន្ធសំខាន់១មានដូចតទៅ:

**<u>មាត្រាទី ៩:</u>**

ធនធានជលផលមានសរីរាង្គទឹកសាប និងសមុទ្រ ជាសត្វ និង រុក្ខជាតិ មានជីវិត ឬគ្មានជីវិត ជាអាទិ៍ មច្ឆជាតិ សិប្បីសត្វ ថលជលិក សត្វបាណកសត្វ ឧរង្គសត្វ ថនិកសត្វ សត្វឥតឆ្អឹងកងផ្សេងទៀតដែលបង្កកំណើតនៅក្នុងទឹក ឬលង់តុង សារាយ ស្មៅសមុទ្រ ផ្កាថ្ម ព្រៃលិចទឹកព្រម ទាំងព្រៃកោងកាងជាដើម។

**<u>មាត្រាទី ១៩:</u>**

តំបន់គ្រប់គ្រងជលផលជា អាទិ៍ តំបន់ទឹកជ្រូរ អន្លង់ជ្រៅនៅតាមដងទន្លេ បឹងទន្លេសាប បឹង ព្រៃលិចទឹក តំបន់កោះ តំបន់ ស្មៅសមុទ្រ តំបន់ផ្កាថ្ម និងព្រៃកោងកាង ដែលជាកន្លែងមានសារៈសំខាន់ដល់និរន្តភាពនៃធនធានជលផលត្រូវរៀបចំចាត់ថ្នាក់ជាកន្លែងការពារ និង អភិរក្សធនធានជលផល។

**<u>មាត្រាទី ២០:</u>**

ហាមឃាត់ដាច់ខាត ចំពោះការធ្វើនេសាទគ្រប់ប្រភេទនៅក្នុងដែននេសាទដោយប្រើឧបករណ៍ដូច ខាងក្រោម:

១- ឧបករណ៍ឆក់ គ្រឿងផ្ទុះ និងសារធាតុពុលគ្រប់ប្រភេទ។

២- ឧបករណ៍បូម បាច ពង្រីងផ្នែកណាមួយនៃដែននេសាទដែលបង្កមហន្តរាយដល់ធនធានជលផល។

៣- សម្រាស់ ឬមធ្យោបាយផ្សេងទៀតដែលធ្វើឱ្យត្រី ឬវារីសត្វកុំ។

៤- ច្បូក សាង ស្ន ឧបករណ៍បាញ់ព្រួញដែលរួមផ្សំគ្រឿងផ្ទុះ។



Draft

៥- មងបោះ មងកាំង ឬ មងពស់ថ្នាន់គ្រប់ប្រភេទ។

៦- មង ឬ អួនគ្រប់ប្រភេទដែលមានក្រឡាតូចជាងមួយសង្ទីម៉ែត្រកន្លះ (១.៥ស.ម) ក្នុងដែននេសាទទឹកសាប

៧- មងគ្រប់ប្រភេទដែលមាក្រឡាធំជាងដប់ប្រាំ (១៥) សង្ទីម៉ែត្រក្នុងដែននេសាទទឹកសាប។

៨- អួនអូសគូ ឬ អួនហ៊ុមរួមផ្សំភ្លើងដែលធ្វើឱ្យត្រី ឬវារីសត្វកុំ។

៩- ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទនៅទឹកសាប។

១០- អួនអូសគ្រប់ប្រភេទនៅទឹកសាប និងឈិបយន្ត។

១១-ព្រួលគ្រប់ប្រភេទដែលមានចន្លោះពីត្រៀមមួយទៅត្រៀមមួយតូចជាងមួយសង្ទីម៉ែត្រកន្លះ (១.៥ស.ម)

១២-ខ្សែចងគ្រប់ប្រភេទ និងមធ្យោបាយផ្សេងៗទៀតដែលបង្កលក្ខណៈឱ្យត្រីផ្អើល។

១៣-ទំនប់រួមផ្សំដោយឧបករណ៍នេសាទគ្រប់ប្រភេទ។

១៤-ឧបករណ៍នេសាទទំនើប ឬ ឧបករណ៍នេសាទដែលបង្កើតថ្មី ឬ របៀបនេសាទបែបថ្មីដែលនាំមកនូវការបំផ្លាញមច្ឆជាតិ ធនធានជលផល ប្រព័ន្ធអេកូឡូស៊ីជលផល ឬ ដែលគ្មានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រាទី ២២:**

ហាមឃាត់ ការចាក់ចោល ការបោះចោល ការបង្ហូរ ឬ ការបាចពង្រាយទៅក្នុងដែននេសាទនូវកាកសំណល់រឹង ឬ រាវ ឬសារធាតុពុលដែលបានកំណត់កោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃព្រះរាជាណាចក្រ កម្ពុជានិងអនុសញ្ញា ឬសន្ធិសញ្ញាអន្តរជាតិស្តីពីការបំពុលបរិស្ថាន ឬការប្រព្រឹត្តិសកម្មភាពដែលធ្វើឱ្យពុល ឬ ការបង្កគ្រោះថ្នាក់ដល់វារីសត្វ និងវារីរុក្ខជាតិ។

**មាត្រាទី ២៥:**

ការធ្វើទំនប់កាត់ ឬ ការលុបទន្លេ ស្ទឹង ព្រែក អូរ បឹង ប្រឡាយ អាងទឹក និងអាងធម្មជាតិ ឬការជីកប្រឡាយ អាងទឹក និងអាងធម្មជាតិ ឬការជីកប្រឡាយរណ្តៅ និងស្រះទ្រង់ទ្រាយ ឬ ការសាងសង់សំណង់ ផ្សេងៗ ថ្មីនានា ឬ ការបូមទឹកដែលអាចបង្កមហន្តរាយដល់ធនធានជលផលនៅក្នុងដែននេសាទ ត្រូវមានការសិក្សា វាយតំលៃពីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថាប័នពាក់ព័ន្ធ។

## ៣) ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក

ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកត្រូវបានអនុម័តដោយរដ្ឋសភាជាតិកម្ពុជានៅក្នុងខែ ឧសភា ឆ្នាំ ២០០៧។ មាត្រាពាក់ព័ន្ធសំខាន់ៗមួយចំនួនទាក់ទងនឹងគំរោងមាន:

**<u>មាត្រា ៣:</u>**

ទឹក និងធនធានទឹកជាសម្បត្តិរបស់រដ្ឋ ។

**<u>មាត្រា ៥ :</u>**

ក្រសួងធនធានទឹក និងឧតុនិយមមានភារកិច្ចគ្រប់គ្រង ដឹកនាំ និងត្រួតពិនិត្យ ក្នុងការអនុវត្តន៏ច្បាប់នេះ។ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយនឹងក្រសួងពាក់ព័ន្ធនានា។ ក្នុងករណីចាំបាច់រាជរដ្ឋាភិបាលអាចនឹងបង្កើតគណៈកម្មការចំរុះចំពោះមុខដើម្បីដោះស្រាយ និងសម្របសម្រួលការងាររវាងបណ្តាក្រសួងពាក់ព័ន្ធ។

**<u>មាត្រាទី ៧:</u>**

ការសហការ និងចូលរួមរបស់ស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជនអ្នកទទួលផលគ្រប់ប្រភេទ អង្គការក្រៅ រដ្ឋាភិបាល និងអង្គការអន្តរជាតិ នឹងត្រូវបានជំរុញដោយរាជរដ្ឋាភិបាលនៅក្នុងសកម្មភាពដែលទាក់ទងទៅនឹងការគ្រប់គ្រងការវិនិយោគ ការធ្វើអាជីវកម្ម ការអភិរក្ស និងការអភិវឌ្ឍន៏ធនធានទឹក ។

**<u>មាត្រាទី ៩:</u>**

ក្រសួងធនធានទឹក និងឧតុនិយម មានភារកិច្ចរៀបចំ និងរក្សាទុកនូវរាល់សារពើភ័ណ្ឌធនធានទឹកនៃព្រះរាជាណាចក្រកម្ពុជា។ សារពើភ័ណ្ឌនេះ បង្ហាញអំពីទីតាំងបរិមាណ និងគុណភាពនៃធនធានទាំងនោះក្នុងរយៈពេលពេញមួយឆ្នាំទៅមួយឆ្នាំ ។

ទិន្នន័យស្តីពីបរិមាណ និងគុណភាពទឹក និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងទឹកដែលស្ថាប័ននានាប្រមូលបានត្រូវបញ្ជូនមកក្រសួងធនធានទឹក និងឧតុនិយមតាមស្តង់ដាបច្ចេកទេស ។

ព័ត៌មាន និងទិន្នន័យខាងលើនេះអាចផ្តល់ជូន បានដោយឥតគិតថ្លៃដល់គ្រប់ស្ថាប័នរាជរដ្ឋាភិបាល និងសហគមន៏នានា ក្នុងទិសដៅបំរើផលប្រយោជន៏សាធារណៈលើកលែងតែព័ត៌មាន និង ទិន្នន័យសម្ងាត់ ។

ក្រសួងធនធានទឹក និងឧតុនិយមអាចតម្រូវឱ្យមានការបង់ប្រាក់ចំពោះពាក្យសុំទាំងឡាយណាដែលធ្វើឡើងក្នុងគោលបំណងអាជីវកម្ម ។

Draft

**<u>មាត្រា ១១ :</u>**

បុគ្គលគ្រប់រូបមានសិទ្ធិប្រើប្រាស់ធនធានទឹកក្នុងបរិមាណមួយមិនលើសពីសេចក្តីត្រូវការចាំបាច់ជាមូលដ្ឋានសំរាប់ការហូបចុក បោកគក់ ងូត និងតំរូវការផ្សេងទៀត រួមមានការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការស្រោចស្រពសួនច្បារ និង ដំណាំ ដោយជៀសវាងមិនអោយមានការប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់អ្នកដទៃ។

**<u>មាត្រា ១២ :</u>**

ការបង្វែរទឹក ការយកទឹក ការប្រើប្រាស់ធនធានទឹក ក្នុងគោលបំណងកសិកម្ម ឬឧស្សាហកម្ម លើសពីកំរិត

ដែលមានចែងនៅក្នុងមាត្រា ១១ និង សំណង់ការងារទឹកដែលពាក់ព័ន្ធ តំរូវអោយមានការសុំអាជ្ញាប័ណ្ណទឹក ឬ លិខិតអនុញ្ញាត។

**<u>មាត្រាទី ២២:</u>**

រាល់ការបញ្ចេញចោល ការទុកចោល ឬការរក្សាទុកនូវសារធាតុពុលដែលអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹក និងអាចបង្កគ្រោះថ្នាក់ដល់មនុស្ស សត្វ និងរុក្ខជាតិត្រូវតែសុំអាជ្ញាប័ណ្ណទឹក ឬ ការអនុញ្ញាត។

ប្រភេទសារធាតុពុលដែលមានចែងខាងលើ និង ស្តង់ដាបច្ចេកទេសនៃការបញ្ចេញទឹកសំណល់នឹងមានកំណត់ដោយអនុក្រឹត្យ។

រាល់កិច្ចដំណើរការក្នុងមាត្រានេះ ក្រសួងធនធានទឹកនិងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនានា។

**<u>មាត្រាទី ២៥:</u>**

ក្នុងករណីដែលពិនិត្យឃើញថា សំណង់ការងារទឹកទាំងឡាយដែលមិនមានស្ថិរភាពគ្រប់គ្រាន់ ឬអាចនឹងបង្កឱ្យមានមហន្តរាយប៉ះពាល់ដល់សង្គមជាតិ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ជា មួយក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានដើម្បីហាមឃាត់ជាបន្ទាន់ទៅតាមសមត្ថកិច្ចរៀង១ខ្លួន។

**<u>មាត្រាទី ៣៩:</u>**

ព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិ និងកាតព្វកិច្ចចាត់ចែងចំណែកសមស្រប និងដោយស្មើភាពក្នុងការប្រើប្រាស់ ការអភិវឌ្ឍន៍ និងការគ្រប់គ្រងទន្លេអន្តរជាតិក្នុងទឹកដីរបស់ខ្លួនស្របតាមសិទ្ធិ និងកាតព្វកិច្ចដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិ ដែលមានព្រះរាជាណាចក្រកម្ពុជាជាភាគី។

ក្រសួងធនធានទឹកនិងឧតុនិយមយកចិត្តទុកដាក់ឱ្យមានការប្រើប្រាស់ទឹកអាងទន្លេមេគង្គលើគ្រប់វិស័យ ដោយរួមទាំងវិស័យដឹកជញ្ជូនផងឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធិភាពស្របតាមគោលការណ៍របស់គណៈកម្មាធិការជាតិទន្លេមេគង្គ។

Draft

## ៨) គោលនយោបាយធនធានទឹកជាតិសំរាប់ព្រះរាជាណាចក្រកម្ពុជា

គោលនយោបាយនេះត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៅសម័យប្រជុំពេញអង្គ ថ្ងៃទី ១៦ មករា ២០០៤។ គោលបំណងរបស់គោលនយោបាយធនធានទឹកជាតិគឺ:

- ដើម្បីការពារ គ្រប់គ្រង និងប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធិភាព សមភាព និង មានលក្ខណៈសមស្រប ។
- ដើម្បីទស្សន៍ទាយ និងធ្វើការវាស់វែងដើម្បីជួយដល់ស្ថាប័នដែលទាក់ទងដោះស្រាយបញ្ហាប្រឈមមុខ ដែល

អាចកើតឡើងនៅក្នុងផ្នែកទឹក ។

- ដើម្បីអភិវឌ្ឍន៍ និងអនុវត្តយុទ្ធសាស្ត្រជាតិ និង បង្កើតគោលនយោបាយជាតិ និង គោលនយោបាយលើវិស័យគ្រប់គ្រងធនធានទឹក ។
- ដើម្បីតំរង់ទិសដល់ការអភិវឌ្ឍន៍ធនធានទឹក ការគ្រប់គ្រង និង ការប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះគ្រប់សកម្មភាពរបស់ស្ថាប័ន ផ្នែកឯកជន និង ផ្នែកសាធារណៈ ។
- ដើម្បីកែលំអ និង លើកកំពស់ការរស់នៅរបស់ប្រជាជន ដើម្បីសំរេចបានតាមគោលនយោបាយជាតិលើការកាត់បន្ថយភាពក្រីក្រ និង ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិអោយមាននិរន្តរភាព។

ម្យ៉ាងវិញទៀត នៅក្នុងផ្នែកទី ៤.២.២ " **ទឹកសំរាប់ថាមពល** " ប្រទេសកម្ពុជាមានសក្តានុពលសំរាប់ការអភិវឌ្ឍន៍ថាមពលវារីអគ្គិសនីប្រហែល ១០០០០ មេហ្គាវ៉ាត់ ដែល ៥០%ស្ថិតនៅក្នុងទន្លេសំខាន់ៗ ៤០% ស្ថិតនៅក្នុងដៃទន្លេ និង ១០% ស្ថិតនៅក្នុងតំបន់ឆ្នេរ ប៉ុន្តែមានត្រឹមតែ ១៣ មេហ្គាវ៉ាត់ប៉ុណ្ណោះដែលបានអភិវឌ្ឍន៍រួចៈ រោងចក្រវារីអគ្គិសនីអូរជុំ (១ មេហ្គាវ៉ាត់) និង រោងចក្រវារីអគ្គិសនីគីរីរម្យ I (១២ មេហ្គាវ៉ាត់) ។ រោងចក្រវារីអគ្គិសនីកំចាយកំពុងស្ថិតនៅក្នុងការសាងសង់ (១៩២មេហ្គាវ៉ាត់) ។ ការអភិវឌ្ឍន៍វារីអគ្គិសនីមានគុណប្រយោជន៍ ក្នុងការផ្តល់ការកាត់បន្ថយភាពក្រីក្រ និង ជំរុញសេដ្ឋកិច្ចកម្ពុជា។ វាមិនត្រឹមតែផ្តល់នូវថាមពលអគ្គិសនីដល់តំបន់ទីក្រុង និងជនបទប៉ុណ្ណោះទេ ប៉ុន្តែអាចបង្កលក្ខណៈងាយស្រួលដល់កសិកម្ម ការការពារទឹកជំនន់ និង កសិ-ឧស្សាហកម្ម នៅក្នុងតំបន់ជនបទផងដែរ ដែលជាទីផ្សារយ៉ាងសំខាន់សំរាប់កសិករ។

ប្រហែល ១៥% នៃចំនួនខ្នងផ្ទះ ក្នុងប្រទេសកម្ពុជាមានអគ្គិសនីប្រើប្រាស់ ហើយជាអគ្គិសនីផលិតពីស្ថានីយ៍ថាមពលដើរដោយប្រេងម៉ាស៊ូត ។

ដើម្បីបញ្ជាក់ពីបញ្ហាខាងលើ និងដើម្បីទទួលបានគុណប្រយោជន៍ពេញលេញពីធនធានទឹក រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅៈ

១- ដើម្បីជំរុញ និង លើកទឹកចិត្តការសិក្សាស្រាវជ្រាវសំរាប់ការអភិវឌ្ឍន៍វារីអគ្គិសនីខ្នាតតូច មធ្យម និងខ្នាតធំលើសក្តានុពលនៃការប្រើប្រាស់ទឹកសំរាប់វារីអគ្គិសនីដោយរាប់បញ្ចូលទាំងតំលៃ និង ផលកំរៃ។

២- ដើម្បីជំរុញការវិនិយោគ និង ការធ្វើអាជីវកម្មនៅគ្រប់កំរិតនៃការអភិវឌ្ឍន៍វារីអគ្គិសនី ដោយរាប់បញ្ចូលអោយគ្រប់តាមរូវការរបស់អ្នកក្រ សហគមន៍តូចៗ និង/ឬ សហគមន៍ដាច់ស្រយាលសំរាប់ការលៃលកប្រើប្រាស់អគ្គិសនី។

ជាងនេះទៀតនៅក្នុងចំនុចទី៣ នៃផ្នែកទី ៤.៥ "ការថែទាំ ការពារ និងនិរន្តរភាពនៃប្រព័ន្ធវារីជាតិ" បានបញ្ជាក់ថា ដើម្បីធានាសុខភាពបរិស្ថានវារីជាតិ ត្រូវរក្សារំហូរ និងកំពស់ទឹកអប្បរមានៃ ទន្លេ ស្ទឹង បឹង ដែលធានាបានសំរាប់ប្រព័ន្ធអេកូឡូស៊ី តំលៃវប្បធម៌និងសង្គម ព្រមទាំងការធ្វើនាវាចរណ៍ ។

Draft

## ៗ) កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការ ដើម្បីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គ, ៥ មេសា ១៩៩៥

នៅក្នុងជំពូកទី III : គោលបំណង និង គោលការណ៍នៃកិច្ចសហប្រតិបត្តិការ

**មាត្រាទី ១: វិស័យនៃកិច្ចសហប្រតិបត្តិការ**

ធ្វើកិច្ចសហប្រតិបត្តិការនៅគ្រប់វិស័យនៃការអភិវឌ្ឍន៍ ការប្រើប្រាស់ ការគ្រប់គ្រង និង ការអភិរក្ស ប្រកបដោយនិរន្តរភាព នៃធនធានទឹក និងធនធានធម្មជាតិ ដែលពាក់ព័ន្ធឯទៀតនៅក្នុងអាងទន្លេមេគង្គរួមជាអាទិ៍ មានការស្រោចស្រព វារីអគ្គិសនី ការធ្វើនាវាចរណ៍ ការត្រួតពិនិត្យ ទឹកជំនន់ ការនេសាទ ការបណ្តែតក្បូនឈើ កន្លែងកំសាន្ត និងទេសចរណ៍ ក្នុងលក្ខណៈធ្វើអោយប្រសើរឡើងនូវការប្រើប្រាស់ចំរុះ និង ផលប្រយោជន៍គ្នាទៅវិញទៅមក របស់ប្រទេសតាមដងទន្លេ និង ដើម្បីកាត់បន្ថយផលប៉ះពាល់អាក្រក់ដែលអាចកើតឡើងពីបាតុភូតធម្មជាតិ និង សកម្មភាពរបស់មនុស្ស។

**មាត្រាទី ២: គំរោង កម្មវិធី និង ផែនការ**

ជួយជំរុញ គាំទ្រ សហការ និង សម្របសម្រួលក្នុងការអភិវឌ្ឍន៍នៃសក្តានុពលទាំងឡាយយ៉ាងពេញលេញនូវផលប្រយោជន៍យូរអង្វែងដល់ប្រទេសតាមដងទន្លេ និងការទប់ស្កាត់ប្រើប្រាស់ទឹកអាងទន្លេ មេគង្គយ៉ាងខ្ជះខ្ជាយ ដោយសង្កត់ធ្ងន់ និង ផ្តល់អាទិភាពដល់ការអភិវឌ្ឍន៍រួម ឬទូទាំងអាងទន្លេ និង កម្មវិធីអាងតាមរយៈការរៀបចំផែនការអភិវឌ្ឍន៍អាងទន្លេដែលត្រូវប្រើប្រាស់ ដើម្បីកំណត់បែងចែក ប្រភេទ និង ធ្វើចំណាត់ថ្នាក់អាទិភាពគំរោង និង កម្មវិធីទាំងឡាយ ដើម្បីស្វែងរកជំនួយសំរាប់គំរោង និងកម្មវិធី និង ដើម្បីអនុវត្តនៅក្នុងកំរិតទូទាំងអាងទន្លេ។

**មាត្រាទី ៣: ការការពារបរិស្ថាន និងតុល្យភាពអេកូឡូស៊ី**

ការពារបរិស្ថាន ធនធានធម្មជាតិ ជីវិត និង លក្ខខណ្ឌវារីជាតិ និង តុល្យភាពអេកូឡូស៊ី នៃអាងទន្លេមេគង្គពីភាពក្រខ្វក់ ឬ ផលប៉ះពាល់អាក្រក់ផ្សេងទៀត ដែលកើតឡើងពីរាល់ផែនការអភិវឌ្ឍន៍ និង ការប្រើប្រាស់ទឹក និងធនធានដែលពាក់ព័ន្ធឯទៀតនៅក្នុងអាងទន្លេ ។

**មាត្រា ៤: អធិបតេយ្យភាពស្មើគ្នា និងបូរណភាពដែនដី**

រួមសហការគ្នាដោយឈរលើគោលការណ៍អធិបតេយ្យភាពស្មើគ្នា និងបូរណៈភាពដែនដីក្នុងការប្រើប្រាស់ និងការការពារធនធានទឹកនៃអាងទន្លេមេគង្គ ។

**មាត្រា ៥: ការប្រើប្រាស់ដោយសមហេតុផល និងដោយសមធម៌**

ប្រើប្រាស់ទឹកនៃប្រព័ន្ធទន្លេមេគង្គដោយលក្ខណៈសមហេតុផល និងប្រកបដោយសមធម៌ក្នុងទឹកដី រៀង១ខ្លួនអនុលោមទៅតាមបណ្តាកត្តា និងកាលៈទេសៈពាក់ព័ន្ធទាំងឡាយ វិធានសំរាប់ការប្រើប្រាស់ទឹក និងការបង្វែទឹកពីអាងទន្លេមួយទៅអាងទន្លេមួយទៀត ដូចមានចែងក្នុងមាត្រា២៦ និងបទបញ្ញត្តិ (ក) និង (ខ) ខាងក្រោមនេះ:



Draft

(ក) លើដៃទន្លេមេគង្គ ដោយរាប់បញ្ចូលទាំងទន្លេសាប រាល់ការប្រើប្រាស់ទឹកនៅក្នុងអាងទន្លេ និងការបង្វែរទឹកពីអាងទន្លេមួយទៅអាងទន្លេមួយទៀតត្រូវតែជូនដំណឹងទៅគណៈកម្មាធិការរួម ។

**(ខ) លើទន្លេមេនៃទន្លេមេគង្គ**

<u>១-នារដូវវស្សា :</u>

ក-ការប្រើប្រាស់ទឹកក្នុងអាងទន្លេត្រូវតែជូនដំណឹងទៅគណៈកម្មាធិការរួម ។

ខ-ការបង្វែរទឹកពីអាងទន្លេមួយទៅអាងទន្លេមួយទៀត ត្រូវតែពិគ្រោះយោបល់ជាមុនក្នុងគោលបំណងស្វែងរកកិច្ចព្រមព្រៀងមួយដោយគណៈកម្មាធិការរួម ។

<u>២-នារដូវប្រាំង :</u>

ក- ការប្រើប្រាស់ទឹកក្នុងអាងទន្លេត្រូវតែពិគ្រោះយោបល់ជាមុន ក្នុងគោលបំណងស្វែងរកកិច្ចព្រមព្រៀងមួយដោយគណៈកម្មាធិការរួម ។

ខ-គំរោងការបង្វែរទឹកពីអាងទន្លេមួយទៅអាងទន្លេមួយទៀត ត្រូវតែបានទទួលការយល់ព្រមពីគណៈកម្មាធិការរួម តាមរយៈកិច្ចព្រមព្រៀងជាក់លាក់មួយសំរាប់គំរោងការនិមួយៗមុននឹងអាចចាប់ផ្តើមគំរោងបង្វែរទឹកណាមួយបាន ។ ក៏ប៉ុន្តែ ប្រសិនបើបរិមាណទឹកលើសសេសសល់ពីសំណើប្រើប្រាស់របស់ភាគីទាំងអស់នារដូវប្រាំងណាមួយនោះដែលត្រូវបានផ្ទៀងផ្ទាត់ និងបញ្ជាក់ជាឯកច្ឆ័ន្ទថា ដូច្នេះមែននោះដោយគណៈកម្មាធិការរួមការបង្វែរទឹកដែលលើសពីអាងទន្លេមួយទៅអាងទន្លេមួយទៀត អាចប្រព្រឹត្តិទៅបានលុះត្រាតែមានការពិគ្រោះយោបល់ជាមុន ។

Draft

**<u>មាត្រាទី ៦:</u> ការរក្សាធារទឹកនៅក្នុងទន្លេមេ**

ធ្វើកិច្ចសហប្រតិបត្តិការដើម្បីរក្សាធារទឹកនៅក្នុងទន្លេមេ ពីការបង្វែរការបញ្ចេញទឹកស្តុក ឬសកម្មភាពផ្សេងៗទៀតដែលមានលក្ខណៈអចិន្ត្រៃយ៍ លើកលែងតែក្នុងករណីមានភាពរាំងស្ងួត និង/ឬ ជំនន់ដ៏ធ្ងន់ធ្ងរ ជាប្រវត្តិសាស្ត្រ:

ក-មិនឱ្យតិចជាងធារទឹកធម្មជាតិអប្បបរិមាប្រចាំខែ ដែលអាចទទួលយកបានសំរាប់ខែនិមួយៗនារដូវប្រាំង ។

ខ-អោយធារទឹកធម្មជាតិដែលអាចទទួលយកបាន ហូរត្រឡប់ចូលទន្លេសាបអាចប្រព្រឹត្តិទៅបាននារដូវវស្សា ។

គ-បង្កាមិនឱ្យមានធារទឹកមធ្យមប្រចាំថ្ងៃច្រើនលើសពីអ្វីដែលធ្លាប់មានជាមធ្យមតាមធម្មជាតិនារដូវទឹកជំនន់ ។

គណៈកម្មាធិការរួមត្រូវអនុម័តរាល់គោលការណ៍ណែនាំអំពីទីតាំង និងកំរិតធារទឹក និងតាមដានត្រួតពិនិត្យព្រមទាំងចាត់វិធានការចាំបាច់សំរាប់ការរក្សាធារទឹកនេះដូចមានចែងក្នុងមាត្រា ២៦ ។